**សុន្ទរកថាស្វាគមន៍**
**ឯកឧត្តម ម៉ៅ ហាវណ្ណាល់**
**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**ថ្លែងក្នុងឱកាសសម្ពោធដាក់ឱ្យប្រើប្រាស់ស្ថានីយអ្នកដំណើរក្នុងស្រុកថ្មី និងសាលថ្មីសម្រាប់ទទួលការមកដល់នៃអ្នកដំណើរអន្តរជាតិ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ**

អាកាសយានដ្ឋានអន្តជាតិភ្នំពេញ ថ្ងៃពុធ ១០រោច ខែ មិគសិរ ឆ្នាំរកា ព.ស ២៥៦១
ត្រូវនឹងថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៧

- សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមគោរព ឯកឧត្តម ប៊ិន ឈិន, ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត ជាទីគោរពរាប់អាន
- ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់
- លោកនីកូឡា ណូតបា (Nicolas Notebaert), អគ្គនាយកក្រុមហ៊ុនសម្បទាន វីអាយអីនស៊ីអាយអ៊ែរផត និងជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ខេមបូឌា អ៊ែរផត
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាទីមេត្រី
- ......................

១. ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានចំណាយពេលវេលាដ៏មមាញឹក អញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ស្ថានីយអ្នកដំណើរក្នុងស្រុកថ្មី និងសាលថ្មីសម្រាប់ទទួលការមកដល់នៃអ្នកដំណើរអន្តរជាតិ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

២. ខ្ញុំសូមឆ្លៀតឱកាសនេះ សម្តែងនូវអំណរសាទរយ៉ាងកក់ក្តៅចំពោះក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានកម្ពុជា ដែលបានខិតខំប្រឹងប្រែងស្តារ និងកែលម្អ អាកាសយានដ្ឋានអន្តរជាតិទាំង៣ នៅក្រោមការគ្រប់គ្រងរបស់ខ្លួនឱ្យមានការរីកចម្រើនជាបន្តបន្ទាប់ ជាពិសេសនៅថ្ងៃនេះ បានសម្រេចនូវការពង្រីកបន្ថែមស្ថានីយអ្នកដំណើរក្នុងស្រុកថ្មី និងសាលថ្មី សម្រាប់ទទួលការមកដល់នៃអ្នកដំណើរអន្តរជាតិ ប្រកបដោយរចនាបថទំនើប គុណភាព សោភ័ណភាព និងផាសុខភាព។ ជាមួយគ្នានេះខ្ញុំក៏សូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលបាននិងកំពុងខិតខំយកចិត្តទុកដាក់បំពេញការងាររៀងៗខ្លួនក្នុងការអភិវឌ្ឍវិស័យអាកាសចរស៊ីវិល ជាពិសេសកិច្ចសហការ និងការសម្របសម្រួលយ៉ាងល្អ ក្នុងភាពជាដៃគូរវាងរដ្ឋ និងឯកជនបានធ្វើគម្រោងនេះសម្រេចឡើងដោយជោគជ័យ។

## - ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី

៣. បន្តិចទៀតនេះលោកអគ្គនាយក នៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានកម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា និងធ្វើសេចក្តីរាយការណ៍លម្អិត អំពីលទ្ធផលចំបង ស្តីពីការវិវត្ត និងដំណើរការនៃការសាងសង់ស្ថានីយអ្នកដំណើរក្នុងស្រុកថ្មី និងសាលថ្មី សម្រាប់ទទួលការមកដល់នៃអ្នកដំណើរ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ រួមទាំងទស្សនទានក្នុងការឆ្លើយតបទៅនឹងចំនួនកំណើនអ្នកដំណើរដែលនឹងកើនឡើងនាពេលខាងមុខ។

៤. ព្រះរាជាណាចក្រកម្ពុជាកំពុងក្លាយជាប្រទេសមួយលេចធ្លោនៅក្នុងតំបន់ ក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ដែលជាប្រទេសមួយមានសន្តិសុខសុវត្ថិភាព និងភាពទាក់ទាញបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ រដ្ឋាភិបាលកម្ពុជាមានទំនួលខុសត្រូវខ្ពស់ក្នុងការរក្សាឱ្យបាននូវស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចប្រកបដោយតម្លាភាព និងក្របខណ្ឌច្បាប់ច្បាស់លាស់ដែលអាចព្យាករណ៍បាន។ យើងនៅតែរក្សាបាននូវកំណើនផលិតផលសរុបក្នុងស្រុកក្នុងរង្វង់ជាង៧%ជាមធ្យម ក្នុងរយៈពេល១០ឆ្នាំខាងមុខ។ ប្រទេសកម្ពុជាទទួលបាននូវកំណើនសេដ្ឋកិច្ចនេះលើសពីការរំពឹងទុក តាមរយៈការចូលរួមជាសមាជិក

អាស៊ាន(ASEAN) និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ជាពិសេសក្នុងគម្រោងគំនិតផ្តួចផ្តើម ផ្លូវ និងខ្សែក្រវ៉ាត់ (Belt and Road Initiative)ដែលបានធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងប្រព័ន្ធពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក ប្រកបដោយភាពរឹងមាំ។

៥. យើងទាំងអស់គ្នាប្រហែលជាដឹងហើយថា ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវកំណែទម្រង់ជាច្រើន ដើម្បីពង្រឹង កែលម្អ និងជួយសម្រួលដល់ការធ្វើធុរកិច្ចនៅក្នុងប្រទេសកម្ពុជា។ កំណែទម្រង់របស់យើងត្រូវបានអនុវត្តស្របទៅតាមគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា បានជំរុញដល់វិស័យឯកជនក្នុងការធ្វើពាណិជ្ជកម្ម សេវាកម្ម និងការវិនិយោគ។

៦. ប្រទេសកម្ពុជា កំពុងប្រែក្លាយខ្លួនជាមជ្ឈមណ្ឌលអាកាសចរណ៍ និងទេសចរណ៍មួយដែលមានភាពទាក់ទាញក្នុងតំបន់ និងពិភពលោក ដែលជាទីតាំងមានភូមិសាស្ត្រល្អប្រកបដោយសក្តានុពល និងសម្បូរបែប ដោយសារប្រទេសកម្ពុជា ជាទីផ្សារមួយក្នុងចំណោមទីផ្សារទេសចរណ៍ ដែលមានការរីកចម្រើនយ៉ាងឆាប់រហ័សបំផុតនៅតំបន់អាស៊ីអាគ្នេយ៍ ហើយដែលនៅតែបន្តរក្សាកំណើនជាមធ្យមក្នុងរង្វង់៨.៥%រហូតដល់ឆ្នាំ២០៤០(IATA Forecast)។ នេះសបញ្ជាក់ឱ្យឃើញថា វិស័យអាកាសចរណ៍កម្ពុជាកំពុងស្ថិតក្នុងលក្ខខ័ណ្ឌមួយដ៏ប្រសើរ និងមានអំណោយផល ក្នុងការធានានូវកំណើនសេដ្ឋកិច្ចជាតិ ប្រកបដោយនិរន្តរភាព។

៧. ការចូលរួមក្នុងភាពជាដៃគូររវាងរដ្ឋ និងឯកជន (PPP) ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បានបើកនូវទំព័រថ្មីបន្ថែមទៀតសម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងការសម្រួលបន្ថែមនូវបរិមាណនៃការមកដល់របស់អ្នកដំណើរតាមផ្លូវអាកាស ប្រកបដោយផាសុកភាពដោយរក្សាបាននូវគុណភាពសន្តិសុខ និងសុវត្ថិភាព ជាពិសេសគឺជួយដោះស្រាយបានបន្ថែមនូវកំណើនចរាចរណ៍អ្នកដំណើរតាមផ្លូវអាកាសក្នុងរយៈពេលមធ្យម និងវែង។ ខ្ញុំសង្ឃឹមថា យើងនឹងបន្តធ្វើការជាមួយគ្នាទៀត ដើម្បីធានាថាអាកាសយានដ្ឋានអន្តរជាតិភ្នំពេញរបស់យើងនឹងរក្សាបាននូវមោទនភាព និងជាទីកន្លែងដែលមិនអាចបំភ្លេចបានមួយ សម្រាប់អ្នកដំណើរជាតិ និងអន្តរជាតិ ក្នុងចំណោមអាកាសយានដ្ឋានអន្តរជាតិនានាក្នុងតំបន់ និងពិភពលោក ។

- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី

៨. ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានកម្ពុជា ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការធ្វើឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត នៅក្នុងវិស័យអាកាសចរស៊ីវិល នាពេលកន្លងមកនេះ ជាពិសេស ខ្ញុំសូមស្នើដល់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន បន្តពង្រឹងនូវកិច្ចសហការណ៍ក្នុងភាពជាដៃគូរកម្រិតជំនាញជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបន្ថែមទៀត ដើម្បីជម្រុញឱ្យវិស័យនេះកាន់តែមានការវិវត្តប្រសើរឡើង។

៩. ជាទីបញ្ចប់ខ្ញុំសូមសំដែងនូងការគោរព និងសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះ **ឯកឧត្តម ម៉ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី និងឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ក្នុងពិធីបើកសម្ពោធដាក់ឱ្យប្រើប្រាស់ស្ថានីយអ្នកដំណើរក្នុងស្រុកថ្មី និងសាលថ្មីសម្រាប់ទទួលការមកដល់នៃអ្នកដំណើរអន្តរជាតិ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាផ្លូវការ សូមមានសុខភាពល្អ ទទួលបានជោគជ័យ លើគ្រប់ភារកិច្ច និងមានសុភមង្គលក្នុងក្រុមគ្រួសារ។

សូមអរគុណ!